


# អាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា២០១៨

## *EDC Young Professionals Scholarship (EYPS)*

ដើម្បីបន្ថែមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងអគ្គិសនីកម្ពុជាផ្ទាល់ តាមរយៈការផ្តល់នូវបទពិសោធន៍ និងចំណេះដឹង ពីឯកទេសដែលខ្លួនបានបញ្ចប់ការសិក្សា អគ្គិសនីកម្ពុជាបានផ្តល់អាហារូបករណ៍តាមរយៈ កម្មវិធីអាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា EDC Young Professionals Scholarship( EYPS ) ដល់និយោជិតអគ្គិសនីកម្ពុជាដែលមានសក្តានុពលទាំងផ្នែកបច្ចេកទេសផ្នែកដឹកនាំ និងជំនាញផ្សេងៗទៀតឲ្យបានបន្តការសិក្សាថ្នាក់អនុបណ្ឌិត ចំនួន ០៣កន្លែង នៅក្រៅប្រទេសដែលជាសមាជិកអាស៊ាន។

### I. ប្រភេទ ឯកទេស និងចំនួនអាហារូបករណ៍

ថ្នាក់អនុបណ្ឌិត ( Master's Degree of Engineering) ផ្នែកអគ្គិសនី

១. Field: Power System Planning ចំនួនៈ០២ កន្លែង

២. Field: Relay Protection ចំនួនៈ០១ កន្លែង

### II. លក្ខខណ្ឌនៃការជ្រើសរើស

-ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)

-ត្រូវមានអតីតភាពការងារនៅអគ្គិសនីកម្ពុជាយ៉ាងតិចចំនួន០៣ឆ្នាំ គិតត្រឹមថ្ងៃស្នើសុំអាហារូបករណ៍

-ត្រូវទទួលបានការអនុញ្ញាតឲ្យសិក្សាជាគោលការណ៍ (Admission in Principles) ពីមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ ដែលសាមីខ្លួនគ្រោងទៅសិក្សាជាមុន។

-ត្រូវមានប្រវត្តិការងារ និងវិន័យល្អចេះធ្វើការជាក្រុមចេះចែករំលែកបទពិសោធន៍ចំណេះដឹងជាមួយអ្នកដទៃ មានស្មារតីគោរពវិន័យចាត់តាំងរបស់អង្គភាព ជាអ្នកមានសក្តានុពលទាំងផ្នែកបច្ចេកទេស និងដឹកនាំសម្រាប់ទៅថ្ងៃអនាគត។

-ត្រូវមានចំណេះដឹងភាសាអង់គ្លេសស្ទាត់ជំនាញ

-ត្រូវមានអាយុក្រោម៣៥ឆ្នាំគិតត្រឹមថ្ងៃឈប់ទទួលពាក្យ

### III. ការផ្តល់អាទិភាព

- ចំពោះនិយោជិតអគ្គិសនីកម្ពុជា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌនៃការជ្រើសរើស ហើយបានដាក់ពាក្យស្នើសុំអាហារូបករណ៍មុនកាលបរិច្ឆេទកំណត់ និងសមស្របទៅតាមតម្រូវការជំនាញចាំបាច់របស់អគ្គិសនីកម្ពុជានឹងត្រូវបានផ្តល់អាទិភាព។
- លើកទឹកចិត្តចំពោះនិយោជិតអគ្គិសនីខេត្តចំណុះឲ្យអគ្គិសនីកម្ពុជា ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នាគឺ ត្រូវផ្តល់អាទិភាព
- លើកទឹកចិត្តចំពោះនិយោជិតអគ្គិសនីកម្ពុជា ឲ្យទៅសិក្សានៅប្រទេសសឹង្ហបុរី ដែលមានគុណភាពនៃការអប់រំខ្ពស់

**បេក្ខជនដែលមានចំណាប់អារម្មណ៍ចំពោះអាហារូបករណ៍ខាងលើ អាចមកទទួលពាក្យស្នើសុំនៅ ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍ នៅរៀងរាល់ម៉ោងធ្វើការ ឬ ចូលទៅកាន់ Website: http://www.edc.com.kh/edcscholarship.php**

**ផុតកំណត់ទទួលពាក្យ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨**

ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍
(ម៉ោងធ្វើការ ៧:៣០-១២:០០, ១៤:០០-១៧:៣០, ពី ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ)
អ៊ីម៉ែលៈ edcscholarship@gmail.com ទូរស័ព្ទលេខៈ ០២៣ ៧២៣ ១៦៣
(អគារ B ជាន់ទី៣) អគ្គិសនីកម្ពុជា #២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ